ការសំភាសន៍របស់ រស់ ចេង

កះ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខះ អ្នកដែរអោយគេសំភាសន៍ រស់ ចេង

កះ ចឹងសំរាប់ខ្ញុំអរគុណច្រើនដែរអ៊ីបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមាន ឈ្មោះថា BYUហាសអ៊ុំ ចឹងដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិជីដូនជីតា ដើម្បីទុកអោយកូនចៅជំនាន់ក្រោយចឹងហាសអ៊ុំ ចឹងនៅពេលដែរខ្ញុំសំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាហាសអ៊ុំដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ បាទចឹងសំរាប់អ៊ុំតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខះ ដាក់បានមានអី

កះ ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងនៅថ្ងៃទី25 ខែ1 ឆ្នាំ2018 ហើយការសំភាសន៍នេះធ្វើនៅភូមិ4 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមនហាសអ៊ុំ នៅរាជធានីភ្នំពេញហាសអ៊ុំ ចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខះ ថាម៉េចទៅ?

កះ ឈ្មោះពេញរបស់អ៊ុំហាស?

ខះ ឈ្មោះរស់ ចេង

កះ ឈ្មោះ រស់ ចេង ចុះអត់អ៊ុំ?

ខះ ទេមានតែមួយនឹង

កះ ចុះកាលពីនៅក្មេងមាននរណាគេហៅអីផ្សេងអត់អ៊ុំ?

ខះ អត់ទេតែប៉ុណ្ណឹងតែម្តងនឹង

កៈ ចុះអ៊ុំអាយុប៉ុន្មានឆ្នាំហើយឥឡូវហោស?

ខៈ ខ្ញុំអាយុ53ឆ្នាំហើយ

កៈ អាយុ53ណាអ៊ុំ ចុះអ៊ុំកើតនៅថ្ងៃណា ខែណា ឆ្នាំណាអ៊ុំមានចងចាំទេ?

ខៈ ខ្ញុំកើតនៅឆ្នាំ1963

កៈ ប៉ុន្តែខែអ៊ុំមានចងចាំទេអ៊ុំ?

ខៈ អត់ចាំទេខែនោះ

កៈ ថ្ងៃទីប៉ុន្មានក៏អត់ចាំដែរហោសអ៊ុំ?

ខៈ បាទអត់ចាំទេ

កៈ ចុះឆ្នាំច័ន្ទគតិអ៊ុំឆ្នាំអីគេដែរអ៊ុំ?

ខៈ បាទថាម៉េច?

កៈ ឆ្នាំច័ន្ទគតិហាសអ៊ុំឆ្នាំអីគេដែរអ៊ុំ?

ខៈ ឆ្នាំកំណើតមែន?

កៈ ឆ្នាំច័ន្ទគតិដូចឆ្នាំជូត ឆ្លូវ ខាល ថោះហាសអ៊ុំ?

ខៈ ឆ្នាំកំណើតឆ្នាំមមែ

កៈ ឆ្នាំមមែណាអ៊ុំ ចុះអ៊ុំកើតនៅភូមិ ឃុំអីគេដែរអ៊ុំ?

ខៈ កើតភូមិល្វា ឃុំគ្រួស

កៈ ស្រុកអីគេអ៊ុំ?

ខៈ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

កៈ ខេត្តស្វាយរៀង អូអ៊ុំមានបងប្អូនចំនួនប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំមានបងប្អូនចំនួន5នាក់

កៈ មាន5នាក់ណាអ៊ុំ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំជាកូនបងគេបង្អស់

ក៖ កូនបងគេណាអ៊ំ ចុះអ៊ំមានដូចជាប្រុសប៉ុន្មាននាក់ ស្រីប៉ុន្មាននាក់អ៊ំមានចងចាំទេអ៊ំ?

ខ៖ មានស្រី2នាក់ ប្រុស3នាក់

ក៖ ចុះបងប្អូនមានឈ្មោះអីគេអ៊ំមានចងចាំទេអ៊ំ?

ខ៖ ចាំតា

ក៖ គាត់មានឈ្មោះបងធំ?

ខ៖ ខ្ញុំមានតែខ្ញុំរស់ ចេង មីកានឿន មីខ្នួន អាបឹង អាខេងប៉ុណ្ណឹង

ក៖ អូបាទអ៊ំចុះអ៊ំមានចងចាំសាច់រឿងអីកាលពីអ៊ំពួកគាត់ហាសអ៊ំ?

ខ៖ គ្មានចងចាំអីទេមានតែមើលគោ មើលអីនឹងមានតែប៉ុណ្ណឹង

ក៖ អូចឹងហោសអ៊ំបាទ?

ខ៖ មានតែទៅមើលគោ ទប់ភ្លឺស្រែប៉ុណ្ណឹង

ក៖ អូបាទចុះកាលពីនៅក្មេងតើអ៊ំចូលចិត្តធ្វើអីគេជាមួយពួកគាត់ដែរអ៊ំ
ជាមួយបងប្អូនរបស់អ៊ំហាសអ៊ំ?

ខ៖ ជាមួយវាមានតែនេះទេលោកគ្រូមានតែមើលគោ ហើយតឿនអោយវាទៅមើលគោ
ហើយដាក់បាយជ្រូក

ក៖ អូមើលគោ ដាក់បាយជ្រូកហោសអ៊ំ ចុះអ៊ំមានធ្លាប់លេងបិទពួនអីជាមួយគាត់អត់អ៊ំ?

ខ៖ ទេមិនដែរទេអាបិទពួននឹងហាស

ក៖ ចុះគប់ឈូស លេងមឹកអីអ៊ំលេងអត់?

ខ៖ អូបើគប់លេង

ក៖ អូលេងគប់ណាអ៊ំ អូលេងគប់ដាក់អីគេដែរអ៊ំ?

ខ៖ កាលណុងលេងគប់ដាក់លុយដាក់មួយកាក់ពីរកាក់

កៈ លេងជាមួយបងប្អូននឹងទៅ?

ខៈ បាទជាមួយបងប្អូនរឺអ្នកដទៃអីចឹងទៅ

កៈ អូបាទអ៊ុំចុះបងប្អូនរបស់អ៊ុំសព្វថ្ងៃគាត់រស់នៅណាដែរអ៊ុំ?

ខៈ នៅផ្ទះទាំងអស់ មកនៅនឹងតែខ្ញុំទេ

កៈ អូចឹងមានន័យថានៅស្រុកណុងទាំងអស់គ្នាតែម្តងហោសអ៊ុំ?

ខៈ បាទនៅទាំងអស់នឹង

កៈ អូចុះពួកគាត់ធ្វើអីគេដែរអ៊ុំ?

ខៈ គេធ្វើសំណង់ទៅធ្វើសំណង់នៅបរទេស

កៈ ទាំងអស់គ្នាតែម្តងហោសអ៊ុំ?

ខៈ បាទទៅទាំងអស់គ្នានឹង

កៈ ចុះមាននរណាគេធ្វើស្រែរឺមួយក៏ធ្វើអីផ្សេងអត់អ៊ុំ?

ខៈ ធ្វើស្រែដល់ពេលដែរដល់ខែធ្វើស្រែវាមកធ្វើចឹងទៅលោកគ្រូ

កៈ អូលក្ខណៈថាដាច់ខែទៅយើងទៅធ្វើសំណង់នៅបរទេស?

ខៈ នឹងហើយដល់ពេលដែរយើងប្រមូលផលអីហើយចឹងហាស

កៈ យើងមកធ្វើស្រែវិញ?

ខៈ នឹងហើយយើងប្រមូលផលអស់ចឹងទៅយើងដាក់ទុកស្រូវអស់ហើយ
ហើយយើងទៅបរទេសណោះអែងចឹងហាស

កៈ អូធ្វើចឹងហោសអ៊ុំ?

ខៈ នឹងទៅបរទេសទៅដើម្បីរកលុយកាក់មកចាយអីចឹង ដើម្បីទិញជីមកព្រុះស្រូវវិញ

កៈ ចុះម្តាយរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ ម្តាយហើ ម្តាយឈ្មោះ ចិន

កៈ ឈ្មោះ ចិន ស្អីគេចិនដែរអ៊ុំ?

ខៈ ស្អីទេញុង ចិនក៏យ៉ាងម៉េចទេនេះ

កៈ ឈ្មោះ ញុង ចិនហោសអ៊ុំ?

ខៈ បាទចឹងហើយនេះ

កៈ ចុះគាត់អាយុប៉ុន្មានដែរអ៊ុំ?

ខៈ គាត់អាយុ70ឆ្នាំជាងហើយនឹង

កៈ ប៉ុន្តែឥឡូវគាត់នៅរស់តាហីអ៊ុំ?

ខៈ គាត់នៅរស់តា ស្លាប់តែឪពុកទើបតែស្លាប់បាន3ខែនឹងហាស ទើបតែធ្វើបុណ្យនឹង

កៈ ម្ដាយគាត់កើតនៅឆ្នាំណាអ៊ុំមានចងចាំទេ?

ខៈ អត់ចាំទេ

កៈ ប៉ុន្តែគាត់អាយុប៉ុន្មានដែរអ៊ុំឥឡូវនឹង?

ខៈ គាត់អាយុ70ឆ្នាំជាងហើយ

កៈ គាត់អាយុចិតប៉ុន្មានដែរអ៊ុំមានដឹងទេ?

ខៈ ថាអាយុ77ឆ្នាំចុះ

កៈ គាត់អាយុ77ឆ្នាំណអ៊ុំ ចឹងគាត់កើតនៅឆ្នាំ1941អ៊ុំ?

ខៈ ប្រហែលជាចឹង

កៈ ចុះម្ដាយរបស់អ៊ុំគាត់ឆ្នាំអី លក្ខណះឆ្នាំជុត ឆ្លូវ ខាល ថោះគាត់ឆ្នាំអ៊ុំអីអ៊ុំ?

ខៈ អូអត់ដែរសួរផង

កៈ អូអត់ដែរបានសួរគាត់ទេណ?

ខៈ បាទៗអត់ដឹង

កៈ ចុះគាត់កើតនៅណាដែរអ៊ុំម្ដាយរបស់អ៊ុំហាស?

ខ៖ គាត់កើតនៅព្រែកល្ពៅ

ក៖ គាត់នៅព្រែកល្ពៅ ចុះនៅឃុំអីគេដែរអ៊ំ?

ខ៖ ព្រែកល្ពៅ នៅឃុំចំបក

ក៖ នៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង?

ខ៖ នៅស្រុកស្វាយជ្រុំ នៅខេត្តស្វាយរៀងដែរនឹង

ក៖ អូបាទអ៊ំ ចុះឪពុករបស់អ៊ំគាត់មានឈ្មោះអីគេដែរអ៊ំ?

ខ៖ គាត់ឈ្មោះ រស់ ឆេង

ក៖ គាត់ឈ្មោះ រស់ ឆេង ចុះគាត់អាយុប៉ុន្មានដែរអ៊ំ ឪពុករបស់អ៊ំ?

ខ៖ គាត់អាយុ77ឆ្នាំហើយ

ក៖ គាត់អាយុ77ឆ្នដែរហោសអ៊ំ ចឹងឪពុកម្ដាយរបស់អ៊ំគាត់អាយុស្មើរគ្នា?

ខ៖ បាទគាត់អាយុស្មើរគ្នាប៉ុន្តែគាត់ស្លាប់ហើយស្លាប់ថ្ងៃមុននេះហើយនឹង

ក៖ អូចឹងមានន័យថាគាត់កើតនៅឆ្នាំ1941ដូចគ្នាណាអ៊ំ?

ខ៖ បាទចឹងហើយ

ក៖ អូបាទអ៊ំចុះឪពុករបស់អ៊ំគាត់កើតនៅណាវិញអ៊ំ?

ខ៖ គាត់កើតនៅល្វា

ក៖ នៅល្វាភូមិល្វា ឃុំអី?

ខ៖ ឃុំគ្រួស

ក៖ នៅឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀងដែរណាអ៊ំ?

ខ៖ បាទៗនឹងហើយ

ក៖ ចុះឪពុករបស់អ៊ំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ំ?

ខ៖ ឪពុករបស់ខ្ញុំកាលពីដើមគាត់ឡើងតែដើមត្នោតនឹង
គាត់ឡើងដើមត្នោតរំងាស់ស្ករហោស

ក៖ អូចឹងមានន័យថាគាត់ចេះកូស្ករហើយ?

ខ៖ បាទគាត់ចេះធ្វើស្កររហូតនឹង

ក៖ ប៉ុន្តែអ៊ុំចេះកូស្ករអត់អ៊ុំ?

ខ៖ ខ្ញុំចេះតា ខ្ញុំឡើងយូរហើយដល់ពេលដៃរលក់ស្ករលែងដាច់ហើយបានខ្ញុំលែងឡើងទៅ

ក៖ បាទអ៊ុំចឹង….?

ខ៖ បាទដល់ពេលវាចាស់ហើយខ្ញុំឡើងលែងរួចហើយ បានតែកូនចៅឡើងនឹង

ក៖ ចុះឪពុករបស់អ៊ុំគាត់ជាមនុស្សបែបណាដែរអ៊ុំ?

ខ៖ អើរគាត់មិនអីទេគាត់

ក៖ គាត់ស្លូតហាសណាអ៊ុំ?

ខ៖ គាត់ស្លូតដែរ

ក៖ អូម្តាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ គាត់នៅផ្ទះហាចិញ្ចឹមមាន់ ចិញ្ចឹមជ្រូកនឹងគ្មានធ្វើអីទេ គាត់បិទស្រា

ក៖ គាត់បិទស្រាដែរហោសអ៊ុំ?

ខ៖ គាត់បិទស្រាដែរនឹង

ក៖ គាត់បិទស្រាយកទៅលក់ណាអ៊ុំ?

ខ៖ គាត់បិទស្រាយកអោយអ្នកនៅភ្នំពេញនឹង

ក៖ អូថ្លៃហីអ៊ុំ?

ខ៖ មួយលីត្របានតែ2000រនឹង

ក៖ ចុះគេលក់នៅណុងបានប៉ុន្មានដែរអ៊ុំ?

ខ៖ បាន1លីត្របាន3000៛ ទៅ3500៛

ក៖ អូប៉ុន្តែយើងដឹកតាមឡានទៅ?

ខ៖ យើងផ្ញើរតាមឡានគេ

ក៖ អូបាទអ៊ុំចុះម្ដាយរបស់អ៊ុំគាត់ជាមនុស្សបែបណាដែរអ៊ុំគាត់ជាមនុស្សស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖ អូគាត់ស្លូតណាស់ តែផ្ទះគេនឹងគាត់មិនដើរផងនៅក្រមុំហោស

ក៖ ចុះឪពុករបស់អ៊ុំគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំអត់អ៊ុំ?

ខ៖ គាត់ប្រាប់តា

ក៖ គាត់ធ្វើអីគេកាលពីគាត់នៅក្មេងហាស?

ខ៖ គាត់កាលពីនៅក្មេងគាត់កៀបតែត្នោតណុងតាគាត់ឡើងត្នោតណុង

ក៖ ចុះម្ដាយរបស់អ៊ុំគាត់ធ្វើអីគេគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់អត់អ៊ុំ?

ខ៖ ប្រវត្តិគាត់មានតែរំងាស់ស្ករឪដាក់មក នឹងធ្វើកន្ទេល

ក៖ អូបាទអ៊ុំ ចុះយាយតាខាងម្ដាយអ៊ុំមានស្គាល់ឈ្មោះគាត់ទេ?

ខ៖ ស្គាល់តា

ក៖ គាត់ឈ្មោះយាយអី តាអីដែរអ៊ុំ?

ខ៖ ឈ្មោះយាយនឿម តាសាល ហើយបើខាងឪពុក ឈ្មោះតាថោង យាយសឹម

ក៖ ឈ្មោះតាថោង យាយសឹម
ចុះអ៊ុំមានដឹងថាយាយតាគាត់កើតនៅឆ្នាំណាអ៊ុំមានចងចាំទេ?

ខ៖ អត់ចាំផង

ក៖ ចុះឪពុកម្ដាយអត់ប្រាប់ទាំងអស់?

ខ៖ បាទអទផងនឹង

កៈ ចុះយាយតា គាត់កើតនៅណាអ៊ុំមានដឹងអត់អ៊ុំ?

ខៈ បាទ បើតានឿម យាយសាល គាត់កើតនៅព្រៃកណ្តៅ

កៈ នឹងនៅខាងម្តាយ?

ខៈ បាទនឹងនៅខាងម្តាយ

កៈ ចុះនៅខាងឪពុកវិញ?

ខៈ នៅខាងឪពុកកើតនៅល្វា

កៈ នៅល្វា ប៉ុន្តែភូមិនៅជិតគ្នាទេណា?

ខៈ អត់ទេបើតារបស់ខ្ញុំតាថោងណុងគាត់កើតនៅបរវិតនោះ

កៈ អូនៅបរវិតហោសអ៊ុំ?

ខៈ នៅបរវិតហោស នៅពោល តានៅពោល

កៈ ចុះឪពុកម្តាយរបស់អ៊ុំគាត់មានធ្លាប់ប្រាប់ប្រវត្តិយាយតាទៅប្រាប់អ៊ុំអត់ទេ?

ខៈ ទេគាត់ប្រាប់ដែរថាអានេះកេរ្តិ៍យើង អានោះកេរ្តិ៍

កៈ លក្ខណៈថាកេរ្តិ៍ពីរតា ពីរយាយចឹងហោស?

ខៈ នឹងហោសថាអាទួលនោះកេរ្តិ៍គេ
អាខ្សែនោះដីរបស់យើងអានោះដីរបស់យើងគាត់បានប្រវត្តិតស៊ូគាត់បានប្រាប់ចឹងដែរនឹង

កៈ ប៉ុន្តែគ្រាន់ថាតា នឹងយាយធ្វើអីទាក់ទងគ្នារបៀបណាៗគាត់អត់បានប្រាប់ទេ?

ខៈ បាទអត់បានប្រាប់ទេ

កៈ ចុះអ៊ុំមករស់នៅភ្នំពេញយូរអត់អ៊ុំ?

ខៈ ខ្ញុំនៅ10ឆ្នាំជាងហើយនឹងបាស

កៈ អូនៅ10ឆ្នាំជាងហើយណអ៊ុំ ចឹងមានន័យថាមិត្តភក្តិរបស់អ៊ុំគាត់មកលេងហើយគាត់មករកការងារធ្វើតែម្តងនឹង?

ខ៖ បាទខ្ញុំមករកធ្វើការងារសំណង់

ក៖ អូបាទអ៊ុំចុះសំរាប់អ៊ុំមានកូនចៅណាដែររស់នៅក្រៅប្រទេសអត់អ៊ុំ?

ខ៖ អត់មានផង

ក៖ ដូចជានៅថៃ វៀតណាមអីអត់មានដែរ?

ខ៖ អត់មានទេ កូនចៅនៅស្វាយរៀងទាំងអស់នឹង

ក៖ ចុះភរិយាយរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ភរិយាឈ្មោះប៉ែន តាមាស

ក៖ ឈ្មោះ ប៉ែន ចុះអ៊ុំរៀបការនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេ?

ខ៖ ការនៅឆ្នាំ82មិនដឹង ដូចថាឆ្នាំ82ចុះ

ក៖ ការឆ្នាំ1982ចឹងអ៊ុំការអស់36ឆ្នាំអ៊ុំ?

ខ៖ បាទការឆ្នាំ82នឹង

ក៖ បាទនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងដូចជាអ៊ុំជាអ្នករៀបចំដោយខ្លួនឯងរឺមួយក៏ឪពុកម្ដាយដែរអ៊ុំ?

ខ៖ ឪពុកម្ដាយជាអ្នករៀបចំអោយ

ក៖ ចុះមានជាជំនូនរឺក៏បណ្ណាការទេអ៊ុំ?

ខ៖ អត់មានទេ មានតែសាច់ជ្រូកមួយភ្លៅ

ក៖ មានសាច់ជ្រូកមួយភ្លៅ?

ខ៖ កាលណុងគេយកសាច់ជ្រូកតែមួយភ្លៅនឹង

ក៖ ហើយម្ហូបអាហារយើងចេញរៀងខ្លួនទៅ?

ខ៖ ហើយម្ហូបអាហារយើងចេញរៀងខ្លួនទៅ រោងការយើងធ្វើដោយខ្លួនទៅ

កៈ អូពេលណុងគេចងដៃអត់អ៊ុំ?

ខៈ គេចងដៃដែរបានមួយកាក់ទៅពីរកាក់ ហោចង500

កៈ អូច្រើនហាសណាស់អ៊ុំ អូអ៊ុំអាចប្រាប់ថាអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយអ៊ុំស្រីនឹង ដូចជាជួបគ្នានៅពេលណា ហេតុអីបានជួបគ្នា គេហៅប្រវត្តិស្នេហាហាសអ៊ុំ?

ខៈ ប្រវត្តិស្នេហាគេហៅជួចត់ មានអីមានតែដឹកក្របីទៅបានជិះលើខ្នងក្របីទៅ

កៈ ជិះជាមួយគ្នាណាអ៊ុំ?

ខៈ អត់ទេគេជាអ្នកដកសំណាប
ហើយយើងចេះតែនិយាយគ្នាទៅមកចឹងទៅហើយស៊ីអាវ្ញូវនឹងទៅ
ហើយនិយាយគ្នាចុះឡើងៗ ហើយបានជាប្រវត្តិជួចត់នឹងតស៊ូនឹង

កៈ ស៊ីអីគេអ៊ុំ ស៊ីវ្ញូវ?

ខៈ ស៊ីវ្ញូវនឹងស៊ីគួរសំណាប

កៈ អូគួរសំណាបហោសអ៊ុំ?

ខៈ ស៊ីគួរសំណាបនឹង

កៈ អូបាទអ៊ុំចុះអ៊ុំស្រលាញ់អ៊ុំស្រីប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរបានការអ៊ុំ?

ខៈ ស្រលាញ់គ្នាបានមួយខែយ៉ាងបានការនឹង

កៈ បានអ៊ុំចូលស្តីអ៊ុំស្រីណាអ៊ុំ ចុះអ៊ុំចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខៈ អត់ចេះផង

កៈ អត់ចេះទេណាអ៊ុំ ?

ខៈ វាពិបាកពេកវាជំលាសទៅខេត្តពោសាត់ហោស

កៈ បាទចឹងអ៊ុំបានរៀនបានថ្នាក់ទីប៉ុន្មានដែរចឹងអ៊ុំ?

ខៈ រៀនបានថ្នាក់ទី2មកនឹងខ្ញុំធំហើយខ្ញុំលែងរៀនខ្ញុំខ្មាស់គេ ខ្ញុំមកពីពោសាត់ ពេលមកពីណុងវិញដើរចង់ស្លាប់ចង់រស់ដើរ3ខែណោះបានមកដល់ផ្ទះ

កៈ បាទអ៊ុំចុះសាលាដែរអ៊ុំរៀននឹងមានឈ្មោះអីគេដែរអ៊ុំ?

ខៈ សាលាកាលេះ

កៈ សាលាកាលេះណាអ៊ុំមានឈ្មោះចឹងតែម្តងអ៊ុំ?

ខៈ បាទឈ្មោះចឹង

កៈ ប៉ុន្តែរៀននឹងសាលានឹងនៅភូមិណាដែរអ៊ុំ?

ខៈ នៅល្វា
ភូមិគ្រួសដែរកាលណុងដូចជាមិនទាន់បានធ្វើតុអីដែរអង្គុយលើដីនឹងអង្គុយលើកន្ទេលនឹង

កៈ ចុះអ៊ុំចេះអានរឺចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ អូអត់សូវចេះទេណាអ៊ុំ
ចុះអ៊ុំចេះភាសាអីក្រៅពីភាសាខ្មែរអត់អ៊ុំ?

ខៈ អត់មានចេះទេ

កៈ ចុះវៀតណាម ថៃ បារាំងអីចេះអត់អ៊ុំ?

ខៈ អត់ចេះទេ

កៈ អត់ចេះដែរណាអ៊ុំ ចុះអ៊ុំមានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាអត់អ៊ុំ?

ខៈ នេះមិត្តភក្តិស្និទ្ធិហើយមិត្តភក្តិ

កៈ អូពួកគាត់ណាអ៊ុំ?

ខៈ បាទនេះបង បងខាងជីដូនមួយដែរ

កៈ ប៉ុន្តែពួកគាត់មានឈ្មោះអីគេដែរអ៊ុំមានចងចាំអត់អ៊ុំ?

ខៈ បាទថាម៉េច?

កៈ អ៊ុំមានចងចាំឈ្មោះមិត្តភក្តិអ៊ុំអត់អ៊ុំ?

ខៈ ខ្ញុំចាំតា ឈ្មោះពៅ ពូយ

កៈ ឈ្មោះពៅ ពូយ អូអ៊ុំប្រុសហោស ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍
រឺក៏ចងចាំសាច់រឿងអីដែរដើរលេងជាមួយគ្នាកាលពីនៅតូចៗអត់អ៊ុំ?

ខ៖ មិនដែរបានដើរទេគ្រាន់តែផ្ទះនៅជិតគ្នានឹង
គ្រាន់ថាល្ងាចចឹងថាទៅណាមកណាចឹងមានតែណាត់បបួលគ្នាចឹងជួបគ្នានៅផ្ទះតែម្តង

ក៖ អូបាទអ៊ុំចុះអ៊ុំមានចងចាំថាទៅស្រែជាមួយគ្នា រឺក៏ធ្វើអីជាមួយគ្នាចឹងហាសអ៊ុំ?

ខ៖ មើលល្ខោនយីកេ

ក៖ បាទលក្ខណះថាទៅមើលល្ខោនចឹងហាសអ៊ុំ?

ខ៖ ទៅមើលល្ខោនមើល
ប៉ុន្តែកាលណុងគេមិនចេះទាស់គ្នាទេចង់ដើរមួយយប់ទល់ភ្លឺក៏បានដែរ
ដើរដេកតាមជ្រាំងនឹង ល្ខោនយីកេ អាយៃកាលណុងគេវៃស្គរទីងទុងៗ

ក៖ មួយណុងដើរដាច់យប់ជាមួយគ្នាណាអ៊ុំ?

ខ៖ ដើរបាទដើរជាមួយគ្នា

ក៖ ហើយលក្ខណះថាគេងជាមួយគ្នាចឹងទៅ អូសប្បាយណាស់អ៊ុំ?

ខ៖ បាទដើរចឹង

ក៖ ចុះអ៊ុំមានធ្លាប់ទៅធ្វើការនៅវាលស្រែទេអ៊ុំ លក្ខណះថាស្រែចំការហាស?

ខ៖ ស្រែចំការមានតែស្នូង មានតែដកនឹង

ក៖ អូបាទអ៊ុំ ចុះអ៊ុំមានធ្លាប់ធ្វើអាជីវកម្មអី រឺចិញ្ចឹមមាន់ ទា ជ្រូក គោ រឺក៏លក់ដូរអីទេអ៊ុំ?

ខ៖ គោកាលពីដើមមាន7-8ក្បាលហោសប៉ុន្តែឥឡូវលក់អស់ហើយនឹង

ក៖ អូលក់អស់ហើយណាអ៊ុំ?

ខ៖ ខ្ញុំបានលក់អស់ហើយ

ក៖ ចុះចិញ្ចឹមមាន់ ទា ជ្រូកអីហោសអ៊ុំ?

ខ៖ មាន់ទាចិញ្ចឹមដាក់ចុះស្លាប់ៗខ្ញុំអត់ដឹងដាក់ចុះទៅ ទិញទៅ

ក៖ ម៉េចចឹងអ៊ុំដាក់អត់កើតចឹងអ៊ុំ?

ខ៖ ដាក់អត់កើតតាំងពីតូចៗមក

កៈ វាមានជំងឺមែនអ៊ុំ?

ខៈ មានជំងឺដឹងក្តីនឹងមកហាស ចាស់ចំណាស់នឹងមកមិនដែលថាបានជ្រូក60គីឡូលក់ទេ មានតែប៉ុណ្ណឹងទេស្លាប់ហើយ បាន20ស្លាប់

កៈ ដល់ពេលស្លាប់ចឹងខាត់ច្រើនហើយអ៊ុំ?

ខៈ គ្មានខាតទេកាប់ស៊ីតែម្តង កាប់ហែងចែកគ្នាស៊ីនឹង

កៈ អូអត់ខាតទេកាប់តែម្តងហោសអ៊ុំ?

ខៈ កាប់ស៊ីខ្លួនអែងចែកគេអ្នកជិតៗខាង

កៈ អូកុំអោយខាតណាអ៊ុំកាប់ខ្លួនអែងតែម្តងនឹង ចុះអ៊ុំធ្លាប់ធ្វើអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំដែរ ដូចជាកាលពីតូចអ៊ុំធ្លាប់ធ្វើអីគេ ហើយឥឡូវនឹងអ៊ុំធ្វើអីគេចឹងហាស?

ខៈ ខ្ញុំកាលពីតូចគ្មានអីទេមានតែមើលគោនឹង

កៈ មើលគោដល់ពេលឥឡូវនឹង?

ខៈ មើលគោ មើលក្របី ដល់ឥឡូវលក់លាស

កៈ លក់លាសណាអ៊ុំ ប៉ុន្តែឥឡូវនៅតែលក់ចឹងណាអ៊ុំ?

ខៈ នៅតែលក់រហូតនឹងទើបតែមកពីលក់មិញនឹង

កៈ អូបាទអ៊ុំ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរទៅអ៊ុំ?

ខៈ ផ្លាស់ប្តូរកាលពីដើមមកយើងធ្វើត្នោត
ដល់ពេលធ្វើត្នោតហើយទៅយើងមកលក់លាសវិញ មកលក់វិញចឹងហាស

កៈ អូបាទអ៊ុំគិតថាអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខៈ មុខរបរផ្លាស់រហូតនឹង

កៈ ប៉ុន្តែម្ហូបអីគេដែរអ៊ុំពិសារហោស?

ខៈ មានតែសាច់ជ្រូកហើយនឹងត្រីនឹង

កៈ ចុះស្លម្ជូ ស្ងោរ ចៀន ឆាអីហោសអ៊ុំ?

ខ៖ ចូលិចិត្តយូរម្តង

ក៖ ជាចំណាង់ចំណូលចិត្តតែម្តងទៅតែម្តងហាស?
ខ៖ យូរម្តងទៅ ថាអោយរាល់ថ្ងៃអត់ទេ

ក៖ ប៉ុន្តែអ៊ុំចូលចិត្ត......?

ខ៖ មានតែខ មានតែស្ងោរ ប៉ុណ្ណឹង

ក៖ អូដែរអ៊ុំចូលចិត្តណាអ៊ុំ
ចុះអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីតាំងពីក្មេងរហូតមកដល់ពេលនេះទៅដែរហាសអ៊ុំ?

ខ៖ ទៅវត្តមានទាញព្រាត

ក៖ ចុះចោលឈូង បោះអង្គុញ លាក់កន្សែងអីហោស?

ខ៖ មានដាក់ទឹកដប់

ក៖ ដាក់ទឹកដប់?

ខ៖ ដាក់បៀម

ក៖ អូដាក់ទឹកដប់បៀមហោសអ៊ុំ ?

ខ៖ មានលោតប៉ារក៏មានអីក៏មាន ស្អីក៏មានដែរសព្វគ្រប់ហើយ បូមទឹកដាក់ដប់នឹង
បៀមទឹកដាក់ដប់នឹងដែរ

ក៖
ចុះអ៊ុំមានចងចាំបទចំរៀងណាដែរអ៊ុំបានរៀនច្រៀងតាំងពីក្មេងរហូតមកដល់ពេលនេះអ៊ុំ
នៅតែចូលចិត្តចឹងហាសអ៊ុំ?

ខ៖ អត់មានទេគ្រូ

ក៖ អត់មានចងចាំអីទេណាអ៊ុំ?

ខ៖ បើចងចាំមានតែខ្ញុំបើស្រលាញ់ជាងគេមានតែស្រលាញ់ស៊ីនស៊ី សាម៉ុតតែម្តង

ក៖ ប៉ុន្តែអ៊ុំមានចងចាំចំណាងជើងបទចំរៀងអត់បង?

ខ៖ ចងចាំមានតែវាលស្រែ វាលស្រូវ ធំធេងនឹង

ក៖ ចុះអ៊ុំអាចដាក់មួយឃ្លាបានទេអ៊ុំ?

ខ៖ អត់អាចដាក់បានទេ

ក៖ ចុះអ៊ុំចូលចិត្តស្តាប់បទចំរៀងអត់?

ខ៖ ចូលចិត្តតា

ក៖ លក្ខណៈបទសម័យរឺបទបុរាណអ៊ុំ?

ខ៖ បទបុរាណ ហើយនឹងភ្លេងការភ្លេងអីចឹងចូលចិត្តតា

ក៖ ចុះអ៊ុំមាននរណានៅក្នុងក្រុមគ្រួសាររបស់អ៊ុំអីចេះលេងឧបករណ៍ភ្លេងអីអត់អ៊ុំ?

ខ៖ មានតែប្អូនរបស់ខ្ញុំមួយនឹង

ក៖ គាត់លេងអីគេដែរអ៊ុំ?

ខ៖ ប្រពីណៃគេចាប់ច្រើងលេងចឹងហាស

ក៖ លក្ខណៈថាវាយខឹមវាយអីនឹងហាស?

ខ៖ ដល់ពេលដែរគេដល់ខែគេផឹកស៊ីគេសប្បាយគេច្រៀងចឹងទៅ វៃប៉ោត វៃអីទៅអានោះ

ក៖ អូលេងវៃប៉ោតណាអ៊ុំ?

ខ៖ បាទរាល់តែថ្ងៃនឹង

ក៖ អូបើលេងភ្លេងខ្មែរអីគាត់ចេះអត់អ៊ុំ?

ខ៖ ចេះតាលេងភ្លេងការរាល់តែថ្ងៃនឹង

ក៖ អូចុះផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស ដូចថានៅពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវផ្ទះយ៉ាងម៉េចចឹងហាស?
ខ៖ ផ្ទះរបស់ខ្ញុំវា
វាអើរវាតូចដែរវាល្មមសម្បនៅចឹងហាសកាលពីមុនវារៀងតូចឥឡូវវាធ្វើបានរៀងទ្រើសបន្តិចទៅចឹងហាស

កៈ នៅផ្ទះរឺក៏ផ្ទះថ្មអ៊ុំ?

ខៈ នៅផ្ទះឈើតើ

កៈ អូចុះផ្ទះរបស់អ៊ុំនឹងដូចជាអ៊ុំជួលគេរឺមួយក៏អ៊ុំសាងសងដោយខ្លួនអែងដែរអ៊ុំ?

ខៈ សាងសងដោយជួលគេនឹង ដើម្បីជួលជាងនឹង

កៈ ជួលជាងប៉ុន្តែអ៊ុំចេះធ្វើផ្ទះទេអ៊ុំ?

ខៈ អត់ចេះទេផ្ទះនោះ

កៈ អូប៉ុន្តែអ៊ុំមានដឹងថាផ្ទះគេប្រើឧបករណ៍អីសំរាប់សាងសងផ្ទះណុងទេអ៊ុំ?

ខៈ មាននរណា មានដែកឈូស មានពន្លាក់ មានពូថៅ មានកាំបិតលួសនោប

កៈ មានដែកគោល មានដែកស័ង្កសីណាអ៊ុំ?

ខៈ មានដែកគោល មានដែកស័ង្កសី

កៈ ធ្វើពីស័ង្កសីរឺមួយក៏ធ្វើពីគ្បឿអ៊ុំ?

ខៈ ធ្វើពីស័ង្កសី

កៈ អូធ្វើពីស័ង្កសីណាអ៊ុំ ចុះអ៊ុំមានជំនាញអីដែរអ៊ុំចេះស្ទាត់ជំនាញតែម្តងហាសអ៊ុំ?

ខៈ ជំនាញដែរចេះស្ទាត់មានអីគេជួលធ្វើបន្តិចបន្តួចនឹង
ធ្វើរោងគោនឹងធ្វើអីចឹងទៅបើនៅផ្ទះ ធ្វើផ្ទះបាយធ្វើគ្រែធ្វើអីចឹងទៅ

កៈ នឹងជាជំនាញដែរអ៊ុំចេះស្ទាត់ចុះអ៊ុំឪពុកម្តាយរបស់អ៊ុំមានបង្រៀនជំនាញអីទៅអ៊ុំអត់អ៊ុំ?

ខៈ ឪពុករបស់ខ្ញុំអត់រៀនផង

កៈ ចុះលក្ខណៈថាវេញវល្លិ៍ ធ្វើស្ករ ធ្វើផ្តៅអីចឹងហាស ធ្វើកន្ទេលអីអ៊ុំចេះអត់អ៊ុំ?

ខៈ អត់ចេះទេ

កៈ ចុះអ៊ុំមានចេះកូរស្ករអត់អ៊ុំ?

ខៈ ចេះកូរស្ករតា

កៈ ចុះអ៊ុំ លក្ខណៈថាកូរស្ករត្នោត ដូចជាឪពុកម្ដាយជាអ្នកបង្រៀនរឺមួយក៏អ៊ុំចេះធ្វើដោយខ្លួនឯងដែរចឹងហាសអ៊ុំ?

ខៈ ធ្វើដោយខ្លួនឯង នឹងចេះតែមើលៗគាត់ទៅ ណាមួយពេលដែរគាត់មកគាត់ចេះតែប្រាប់ថានេះអាស្ករនេះគេពុះចេះ នេះទឹកនោមគោកុំដើរចោលហាស

កៈ ទឹកនោមគោ?

ខៈ នឹងហើយអើរកុំដុតភ្លើងខ្លាំង ប្រយ័ត្នខ្លាចរឹងឥឡូវហើយប្រយ័ត្នខ្លោចហាស

កៈ ចុះអ៊ុំអាចប្រាប់បានទេអ៊ុំថាពេលណាដែរអ៊ុំគិតថាជាពេលដែរការលំបាកនៅក្នុងជីវិតរបស់អ៊ុំបានទេ ថានៅពេលណាចឹងហាសអ៊ុំ?

ខៈ អើរពិបាកណាស់ពិបាកតាំងពីកៅជាងមកម្ល៉េស ប្រវត្តិដើរមកតាំងពីខេត្តពោសាត់មកចឹងបានជាមិនដចង់និយាយនឹង ដើរអស់3ខែ ដើរពីពោសាត់មកដើរមកដល់ខេត្តស្វាយរៀងអស់រយៈពេល3ខែ

កៈ អូអស់រយៈពេល3ខែហោសអ៊ុំ?

ខៈ អស់3ខែគត់ឡើងពងជើង យូរៗទៅយកអាក្រទបជើងនឹងរុំចេះទៅ

កៈ អូអាក្រទបចេកអីនឹងហោសអ៊ុំ?

ខៈ ទេអាក្រណាត់យើងនឹង អូដើរប្រវត្តិតស៊ូអស់ទាស់ហើយខ្ញុំនោះ

កៈ យើងដើរចឹងលក្ខណៈជាគ្នាជាក្រុមរឺមួយក៏ដើរដោយម្នាក់ឯងដែរអ៊ុំ?

ខៈ ដើរជាហ្វូង ដូចហ្វូងគោចឹងប្រវែងណាណតាំងពីនេះចឹងរហូតដល់ស្ពានច្បារអំពៅណមែនជិតណាកាលណុង

កៈ ហើយចុះម្ហូបអាហារយើងធ្វើយ៉ាងម៉េចទៅអ៊ុំ?

ខៈ ម្ហូបអាហារយើងធម្មតា

កៈ យើងស្គាយរៀងខ្លួនចឹងទៅ?

ខៈ យើងស្គាយរៀងខ្លួនទៅ

កៈ ដល់ពេលដែរដល់យប់ពេលណាយើងធ្វើអីហូបជុំគ្នាចឹងទៅ?

ខៈ អត់ទេបាយដោយខ្លួននឹង

កៈ ប៉ុន្តែជាមិត្តភក្តិរបស់យើងរឺក៏មិនដែរស្គាល់គ្នាដែរអ៊ុំ?

ខៈ អត់ដែរស្គាល់គ្នាផងនឹង

កៈ ប៉ុន្តែគោលបំណងរបស់យើងទៅណុងទាំងអស់គ្នាចឹងទៅ?

ខៈ ទៅណុងទាំងអស់គ្នាគេជំលាសពីជំនាន់ពលពត ពលពតគេជំលាសទៅណុង

កៈ ចុះកាលពីជំនាន់ពលពតអ៊ុំពិបាកអីគេខ្លះទៅអ៊ុំអាចប្រាប់ខ្ញុំបានទេអ៊ុំ?

ខៈ ពិបាកណាស់ឃ្លាលសេះ ណាមួយអាកាអូសហែងសឹកមុខអស់ហើយ

កៈ ចុះអ៊ុំគេអោយទៅណាដែរទៅអ៊ុំកាលពីជំនាន់ពលពតហាសអ៊ុំ?

ខៈ អោយទៅពោសាត់

កៈ អោយទៅពោសាតណាអ៊ុំ ចុះក្រុមគ្រួសារគេអោយទៅណាដែរទៅអ៊ុំ?

ខៈ ក្រុមគ្រួសារគេអោយនៅផ្សេង ខ្ញុំគេអោយនៅផ្សេងនៅសហាករផ្សេងទៅ

កៈ អ៊ុំនៅតែម្នាក់អែងនៅពោសាត់នឹង?

ខៈ បាទខ្ញុំនៅម្នាក់អែងនឹង

កៈ ចុះបងប្អូនរបស់អ៊ុំនៅជាមួយក្រុមគ្រួសារ?

ខៈ បាទវានៅតូចៗ

កៈ ជុះរបបអាហារអីយ៉ាងម៉េចដែរអ៊ុំ?

ខៈ របបអាហារមិនសូវអីទេណុង

កៈ ដោយសារតែអ៊ុំធ្វើកងទ័ពនៅណុង?

ខ៖ អត់ទេឃ្វាលសេះអោយគេ

ក៖ អូឃ្វាលសេះអោយគេណាអ៊ុំ
ចុះប៉ុន្តែអ៊ុំមានបានប្តូទីលំនៅអីផ្សេងអោយទៅណាទៀតអត់អ៊ុំ កាលពីជំនាន់ណុងហាសអ៊ុំ?

ខ៖ អត់ទេ

ក៖ ធ្វើនៅណុងរហូតទាល់តែដាច់ពលពតណុងតែម្តងនឹង?

ខ៖ អត់ទេទាល់តែបែកហើយបាននាំគ្នាមកវិញនឹង

ក៖ ហើយបានដើរមកគ្នាច្រើននឹងហោសអ៊ុំ?

ខ៖ បាទកាលណាទៅវាវៃទៅវាពាក់កណ្តាលទៅ
វាសំលាប់រាប់រយចឹងទៅមើលតែមិនស្រួលវាបាញ់ចោលតែម្តងទៅ

ក៖ បាទអ៊ុំចុះជំនាន់ខ្មែរក្រហមអ៊ុំធ្វើអីគេដែរទៅអ៊ុំ?

ខ៖ ជំនាន់ខ្មែរក្រហមគ្មានធ្វើអីទេមកផ្ទះហើយនឹង

ក៖ អូផុតហើយណាអ៊ុំ?

ខ៖ បាទផុតហើយកាលខ្មែរក្រហមនឹង

ក៖ ប៉ុន្តែពេលណុងអ៊ុំមានប្រកបមុខរបររកស៊ីអីគេដែរទៅអ៊ុំ?

ខ៖ មុខរបរថាឡើងដើមត្នោតនឹង

ក៖ បាទប៉ុន្តែពេលណុងគេចាយលុយហើយមែនទេអ៊ុំ?

ខ៖ បាទពេលណុងគេចាយហើយនឹងចាយមួយកាក់ពីរកាក់

ក៖ បាទអ៊ុំចុះអ៊ុំឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖ អូលំបាកវេទនាណាស់ខ្ញុំនឹងមិនបាច់និយាយទេ

ក៖ ដូចជាអ៊ុំឆ្លងកាត់វាយ៉ាងម៉េចដែរ ហើយអ៊ុំជំនះដោយរបៀបណាដែរចឹងហាសអ៊ុំ
ដូចជាការតស៊ូអីចឹងហាសអ៊ុំ?

ខ៖ តស៊ូលំបាកវេទនាណាស់

កៈ ចឹងហោសអ៊ុំ ចំអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់អ៊ុំដែរចឹងហាសអ៊ុំ ដូចជាពេលដែរការកូន រឺមួយក៏សារខ្លួនអែងចឹងហាស?

ខៈ កាលការកូនខ្លាចតែមួយទេ

កៈ ខ្លាចតែខ្វះម្ហូបនឹងមែនអ៊ុំ?

ខៈ ខ្លាចខ្វះម្ហូប ហើយខ្លាចរឿងចំណងដៃគេចឹងទៅខ្លាចជំពាក់គេទៀតនឹង មានតែពីរនឹងទេ

កៈ អូប៉ុន្តែការខ្លួនអែងអ៊ុំ?

ខៈ បាទថាយ៉ាងម៉េចដែរ?

កៈ ការខ្លួនអែងវិញអ៊ុំ?

ខៈ ការខ្លួនអែងវាមិនអីទេពីព្រោះលុយវានៅថ្លៃដែរនឹង កាលការខ្លួនអែងនឹងមិនអីទេយើងទិញតែ600នឹងបានក្របីមួយតែ300នឹង កាលណុងស៊ីក្របីមួយ300 នឹងជ្រូកមួយកាលណុងដូចជា200រឺមួយក៏100ទេនេះភ្លេចដែរហើយនឹងជាមួយឪពុក

កៈ បាទអ៊ុំ ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាមួយមិត្តភក្តិរឺជាមួយអ៊ុំប្រុសអីទៅស្រែទៅអីដែរអ៊ុំគិតថាអ៊ុំចាំមិនភ្លេចហាសអ៊ុំ?

ខៈ ចាំមិនភ្លេចមានតែឡើងពីស្ទូងចឹងទៅឡើងទៅ ដល់ពេលដែរម៉ោង8-9បាយជុំគ្នាចឹងទៅនៅស្រែស្ទូងនឹងសប្បាយណាស់

កៈ អូនឹងជាពេលដែរសប្បាយជាងគេដែរអ៊ុំចាំមិនភ្លេចហើយនឹងហោសអ៊ុំ?

ខៈ បាទសប្បាយហាស

កៈ ចុះអ៊ុំមានគិតថាមានក្តីស្រម៉ៃថាតាំងពីក្មេងរហូតមកដល់ពេលនេះហាស គិតថាអ៊ុំចង់ធ្វើអីមួយអីដែរពេលធំឡើងទេអ៊ុំ?

ខៈ អ្វីដែរចង់បានចេះតែចង់បានហើយគ្រាន់តែមិនសូវជាមានលុយនឹង

កៈ ចុះអ៊ុំកាលណុងអ៊ុំចង់ធ្វើអីគេដែរអ៊ុំ?

ខៈ មុខរបរដែរចង់បើកមើល
បើកចាប់ហួយបើកអីចឹងទៅដល់ពេលដែរយើងវាគ្មានអីកាលណុងចឹងហាសគ្រូ

កៈ ប៉ុន្តែអ៊ុំចង់ធ្វើជាគ្រូពេទ្យ ចង់ធ្វើជាគ្រូបង្រៀន
ចង់ធ្វើជាកងទ័ពរឺក៏ចង់ធ្វើជាប៉ូលីសចឹងហាស?

ខៈ ខ្ញុំមិនចង់បានទេចឹងខ្ញុំស្អប់ណាស់ អាប៉ូលីសអីនឹង

កៈ អូប៉ុន្តែអ៊ុំធ្លាប់គិតថាចង់ធ្វើជាទាហ៊ានធ្វើអីអត់?

ខៈ ទាហ៊ានវាឆ្អែតណាស់ហើយនឹង

កៈ
ចុះបើចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយរបស់អ៊ុំតើអ៊ុំចង់ផ្តែផ្តាំអីទៅពួកគាត់ដែរអ៊ុំ?

ខៈ ផ្តែផ្តាំថាធ្វើយ៉ាងម៉េចកុំអោយពិបាកវេទនាដូចឪចឹង
នឹងហើយអោយខំរៀនសូត្រអោយខំអីណាមួយ កុំអោយដូចឪវេទនាឈ្លើងខាំចង់ស្លាប់
គេដេញចាប់ដេញអីយប់ព្រលប់ហោស ចាប់កប្រាំងចាប់អីចង់ស្លាប់ហើយ

កៈ នៅណាវិញអ៊ុំពេលណុង?

ខៈ នៅខេត្តស្វាយរៀងចាប់ស្រាត់ទៅចំពងហែងនឹងធំមួយខាងម៉េស
ឈ្លើងប៉ុននេះខាំឡើងឆ្អែត

កៈ ពេលណុងនឹងពេលណាដែរអ៊ុំ?

ខៈ ពេលកៅជាងនឹង

កៈ ពេលកៅជាងចុះនរណាគេអោយអ៊ុំទៅដែរអ៊ុំ?

ខៈ ប្រធានភូមិគេដេញចាប់

កៈ គេដេញចាប់យើងហោសអ៊ុំ?

ខៈ ដេញចាប់យើងនឹង

កៈ ម៉េចបានជាគេដេញចាប់យើងចឹងអ៊ុំ?

ខៈ យើងគេចវេសមិនព្រមទៅធ្វើទាហ៊ាន

កៈ អូគេចាប់យើងយកទៅធ្វើជាទាហ៊ានហោសអ៊ុំ?

ខៈ នឹងហើយគេចាប់យកទៅធ្វើកប្រាំនឹង

កៈ ដល់ពេលនឹងពេលដែរយើងអត់ទៅចឹងទៅយើងក៏ភៀសខ្លួនទៅៗៗ?

ខៈ យើងភៀសទៅនេះទៅនោះ

កៈ ឆ្លងកាត់ស្រែឆ្លងកាត់អីចឹងទៅ?

ខៈ នឹងហើយទំរាំបានយប់នឹងថាវាវេទនាចឹងទៅ
ទំរាំបានយប់មួយយប់នឹងពិបាកវេទនាណាស់ហើយ មិនហ៊ានមកដេកផ្ទះទៀតនឹង

កៈ នឹងគេចាប់តែកូនប្រុសទេណាអ៊ុំ?

ខៈ បាទនឹងតែកូនប្រុសទេកូនស្រីគេមានទៅអីគេ

កៈ អូចុះបងប្អូនរបស់អ៊ុំគាត់រត់ដូចតែអ៊ុំចឹងដែរទៅ?

ខៈ រត់ៗដូចតែគ្នានឹងប៉ុន្តែទាស់វានៅតូចៗធំតែខ្ញុំពីរនាក់នឹង

កៈ ប៉ុន្តែអ៊ុំរត់ផ្សេងគ្នាអ៊ុំរត់ទៅផ្សេងទៅ ប្អូនរបស់អ៊ុំរត់ទៅផ្សេងចឹងទៅ?

ខៈ បាទរត់រហូតនឹង

កៈ ប៉ុន្តែពេលណុងចាប់អ៊ុំអត់បានដើម្បីធ្វើជាទាហ៊ានណាហីអ៊ុំ?

ខៈ គេចាប់អត់បានទេ

កៈ ប៉ុន្តែប្អូនរបស់អ៊ុំចាប់បានទេ?

ខៈ ប្អូនរបស់ខ្ញុំចាប់បាន

កៈ ចឹងក៏ទៅធ្វើជាទាហ៊ានចឹងទៅ?

ខៈ ទៅធ្វើជាទាហ៊ានទៅមកវិញដើរដួល តេកតាក់ៗចាញ់

កះ ប៉ុន្តែពេលណុងអ៊ុំរត់ចូលព្រៃទៅគេងជាមួយមិត្តភក្តិរបស់អ៊ុំទៅហោសអ៊ុំ?

ខះ រត់ទៅគេងនៅព្រៃ ទៅពួននៅដើមត្នោតទៅពួនអីវិននឹង នៅក្រលៀតក្រលោះ នៅដើមអំពិលដើមអីចឹងទៅ យប់ដេកជាមួយមិត្តភក្តិពួកម៉ាក់ចឹងទៅ មានប្រម៉ាន់5-6-7នាក់ចឹងទៅ

កះ ចុះពេលណាដែរឈប់ចាប់យើងយកទៅធ្វើជាទហ៊ានទៅអ៊ុំ?

ខះ កាលណុងប្រម៉ាន់ភ្លេចទៅឆ្នាំណុង

កះ ប៉ុន្តែដូចជាឆ្នាំណាដែរគេឈប់ហាស ដែរគេអោយយើង?

ខះ វាភ្លេចអាឆ្នាំឈប់នឹងហាស

កះ ដែរធ្វើអោយស្រុកយើងសន្តិភាពតែម្តងហាស?

ខះ សន្តិភាពពេលណាដែរទេភ្លេចទៅណាបើកទូរទស្សន៍ ស្រុកសន្តិភាពនឹងដូចជាឆ្នាំ1991នឹងពេលដែរសម្តេចតាចូលស្រុកនឹង

កះ ដោយសារតែសម្តេចតាចូលស្រុកនៅឆ្នាំ1991?

ខះ អូចឹងឆ្នាំណុងហើយចឹងនោះ

កះ ពេលណុងពេលដែរសម្តេចតាចូលមកយើងលែងមានអីហើយណាអ៊ុំ ពេលណុងយើងសប្បាយទាំងអស់គ្នាហើយណាអ៊ុំ?

ខះ ណុងហើយពេលណុងនឹង

កះ ចឹងសំរាប់អ៊ុំមានចង់ផ្តែផ្តាំអីទៅកូនចៅជំនាន់ក្រោយៗទៀតអត់អ៊ុំ មានអីផ្សេងទៀតទេអ៊ុំដែរអ៊ុំចង់ផ្តែផ្តាំទៅពួកគាត់ដើម្បីអោយពួកគាត់អាច មានជីវិតមួយដែរល្អ ហើយនឹងមានការងារអីដែរល្អដែរអ៊ុំចង់ផ្តែផ្តាំចឹងហាសអ៊ុំ?

ខះ គ្មានអីទេប៉ុណ្ណឹងអែង

កះ ចឹងមានតែប៉ុណ្ណឹងទេណាអ៊ុំ?

ខះ បាទមានតែប៉ុណ្ណឹង

កះ ចឹងជាចុងក្រោយសំរាប់ខ្ញុំអរគុណច្រើអ៊ុំដែរមានអោយខ្ញុំ
ពិភាក្សាជាមួយខ្ញុំដែរទាក់ទងជាមួយនឹប្រវត្តិរបស់អ៊ុំ
ហើយខ្ញុំអរគុណច្រើនដែរអ៊ុំបានផ្តល់ប្រវត្តិមួយនឹងទៅអោយខ្ញុំចឹងហាសអ៊ុំ
បាទអរគុណច្រើនណាអ៊ុំ៕៕៕